ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈករណីស្រាវជ្រាវស៊ើបអង្កេត ការកសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ	ប្រធាន
២-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល អគ្គស្នងការរងនគរបាលជាតិ	សមាជិក
៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ ស៊ិន្ធ ម៉ិន ប្រធាន ក២ កងទ័ពជើងគោក	សមាជិក

ប្រការ ២ : គណៈករណីនេះមានភារកិច្ច :

-ពិនិត្យ ស្រាវជ្រាវ ស៊ើបអង្កេត រាល់សកម្មភាព កសាងកំលាំងខុសច្បាប់ និងការដាក់គ្រឿងផ្ទុះ ដែលមានជនល្មើសឈ្មោះ សោម ឯក ជាមេក្លោង ។

-ប្រមែប្រមូលឯកសារ វត្ថុតាងផ្សេងៗ ទាក់ទងដល់សកម្មភាពខាងលើ

-ធ្វើការប្រជុំបូកសរុប វាយតំលៃ រួចរាយការណ៍ពីលទ្ធផលជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីរាយការណ៍ជូនសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីពិនិត្យ និងមានវិធានការតាមការជាក់ស្តែង ។

www.pheakdeylaw.com

ប្រការ ៣ : គណៈករណីនេះមានសិទ្ធិប្រើប្រាស់កងកំលាំងក្រោមឱវាទរបស់ខ្លួន ដើម្បីបំពេញភារកិច្ចខាងលើតាមការចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងទ័ពជើងគោក និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com